

# ម៉ាក់ គឺ កំពូលស្ត្រី

HerStory Foundation
Inshra Sakhawat Russell

Let's Read
The Asia Foundation




មាន វីរនារីដ៏ពិសេសម្នាក់ ជាអ្នកសង្គ្រោះជីវិតមានឈ្មោះថា កំពូលស្ត្រី។ គាត់ប្រឆាំងនឹងឧក្រិដ្ឋកម្ម ការពារអ្នកទន់ខ្សោយ និងដាក់ទោសមនុស្សអាក្រក់។ គ្មាននរណាម្នាក់ស្គាល់អត្តសញ្ញាណគាត់ឡើយ...លើកលែងតែខ្ញុំ! ខ្ញុំបានរកឃើញថា កំពូលស្ត្រីជាម៉ាក់របស់ខ្ញុំ។ បងប្រុសខ្ញុំគិតថាខ្ញុំឆ្កួត គាត់និយាយថាម៉ាក់របស់យើងដូចតែមនុស្សគ្រប់គ្នាដែរហ្នឹង។ ចុះរ៉ូបឆេះមួយ ដែលខ្ញុំឃើញក្នុងទូខោអាវរបស់ម៉ាក់ នៅថ្ងៃបន្ទាប់ ក្រោយពីកំពូលស្ត្រីព្យាយាមជួយពន្លត់ភ្លើងដែលឆាបឆេះរោងចក្រជិតនេះ យ៉ាងម៉េចដែរ? នៅមានស្នាមលើដៃរបស់គាត់ បន្ទាប់ពីជួយសង្គ្រោះសត្វដែលគេចាប់ទៅ វា

យ៉ាងម៉េចវិញ?



ទីបំផុត យប់មិញខ្ញុំក៏លួចតាមទៅមើលម៉ាក់ ពេលគាត់ចេញពីធ្វើការ។ ខ្ញុំរំពឹងថាគាត់នឹងចេញទៅបន្ទប់សម្ងាត់ ពោរពេញទៅដោយសម្ភារៈទំនើបៗរបស់គាត់ ផ្ទុយទៅវិញ គាត់បែរជាទៅបន្ទប់តូចមួយ ដែលមានមនុស្សស្រីជាច្រើនទៀតដូចជាគាត់។ គាត់អង្គុយនៅមុខម៉ាស៊ីនដេរមួយ ហើយចាប់ផ្តើមធ្វើការ។ ខ្ញុំសម្លឹងមើលគាត់ដេរខោអាវយ៉ាងយូរ។ គាត់ពូកែដេរណាស់ តែយូរទៅខ្ញុំក៏ឃើញថាគាត់ក៏ហត់ណាស់ដែរ។



ខ្ញុំលង់លក់ តែត្រូវភ្ញាក់ដោយសារសំឡេងកណ្តឹង។ ខ្ញុំប្រញាប់រត់ទៅផ្ទះចូលក្នុងបន្ទប់គេង បានមុនពេលម៉ាក់ត្រឡប់មកដល់ផ្ទះវិញបន្តិច។ ពេលគាត់ចូលមកមើលខ្ញុំ ខ្ញុំពិតជាចង់ប្រាប់គាត់ថា ខ្ញុំតូចចិត្តណាស់ដែលម៉ាក់មិនមែនជាអ្នកធ្វើការនៅកន្លែងដែលមានបច្ចេកវិទ្យាទំនើបដើម្បីកម្ចាត់សភាវៈអាក្រក់។ ខ្ញុំចង់តែស្រែកយំ តែព្យាយាមបិទភ្នែកទៅវិញ ហើយធ្វើពុតជាគេងលក់។



សំណាងណាស់ដែលខ្ញុំមិនបាននិយាយអ្វី! ពេលព្រឹកឡើង ខ្ញុំបានឃើញម៉ាក់ដើរមើលជុំវិញផ្ទះ ជូសជុលអីវ៉ាន់មួយចំនួនផង ចម្អិនម្ហូបផង និងជួយដោះស្រាយលំហាត់កិច្ចការផ្ទះរបស់ពួកយើងផង។ គាត់ពិតជារហ័សណាស់ ដែលអាចស្ទុះទៅចាប់បានពែងរៀបនឹងធ្លាក់ ហើយធ្វើការងារជាច្រើនមុខក្នុងពេលតែមួយ ដោយស្នាមញញឹមយ៉ាងសប្បាយរីករាយ។ ម៉ាក់ដូចជាមិននឿយហត់សោះ ទាំងដែលទើបបំពេញការងារដេរកាលពីយប់មិញ! ម៉ាក់ពិតជាពូកែធ្វើការងារទាំងនេះណាស់ ហើយពេលនេះខ្ញុំប្រាកដហើយថា គាត់គឺជាកំពូលស្ត្រី។



ឥឡូវនៅពេលដែលខ្ញុំមើលទៅក្រៅបង្អួច ខ្ញុំឃើញ កំពូលស្ត្រីរាប់លាននាក់។ ម្នាក់ៗសុទ្ធតែអស្ចារ្យដូចម៉ាក់របស់ខ្ញុំដូច្នេះដែរ។ ហើយខ្ញុំក៏ដឹងថា ពេលខ្ញុំធំឡើង ខ្ញុំនឹងពូកែ ហើយរឹងមាំ។ ថ្ងៃណាមួយ ខ្ញុំនឹងធ្វើឱ្យមានការផ្លាស់ប្ដូរ ទោះជារឿងតូចក្ដី ធំក្ដី ព្រោះថាបើមិនមែនខ្ញុំ តើនរណាជាអ្នកធ្វើ?

សាច់រឿងដ៏បំផុសគំនិតមួយនេះជាផ្នែកមួយនៃ ការប្រមូលផ្តុំរឿងទាំងឡាយរបស់ស្រ្តីបង្កើតឡើងដោយមូលនិធិHerStory និងដាក់ជាសៀវភៅដាច់ដោយឡែកក្នុងកម្មវិធី តោះអាន ក្រោមការសហការរបស់មូលនិធិអាស៊ី។

សម្រាប់ព័ត៌មានបន្ថែមលើ HerStory សូមចូលទៅកាន់គេហទំព័រ
www.herstorybd.org

## Brought to you by

The Asia Foundation

Let’s Read is an initiative of The Asia Foundation’s Books for Asia program that fosters young readers in Asia and the Pacific.
booksforasia.org
To read more books like this and get further information about this book, visit letsreadasia.org

**Original Story**

*আমার মা - সুপারনোভা (The Supernova: Mom)*, Author: HerStory Foundation. Illustrator: Inshra Sakhawat Russell. Released under CC BY-NC 4.0.

This work is a modified version of the original story. © The Asia Foundation, 2020. Some rights reserved. Released under CC BY-NC 4.0.

For full terms of use and attribution,
http://creativecommons.org/licenses/by-nc/4.0/